ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ

នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧២៧ អពដ

# សេចក្ដីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដំណឹងដល់ អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាអភិបាលឬបណ្ណាធិការសហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(របបពិត)ឲ្យបានជ្រាបថា អនុលោមតាមមាត្រា២៩ នៃច្បាប់ស្ដីពីសារពើពន្ធ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំជាប់ពន្ធណាមួយ ក្នុងរយៈពេល ៣ ខែ ក្រោយដំណាច់ឆ្នាំជាប់ពន្ធនោះ ។

សម្រាប់ឆ្នាំជាប់ពន្ធ ២០១១ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ រួមមានតារាងតុល្យការ គណនីលទ្ធផល តារាងព័ត៌មានបន្ថែម និងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១២ ។

អាស្រ័យដោយរយៈពេលដូចបានជម្រាបជូនខាងលើជិតផុតកំណត់ហើយនោះ អគ្គនាយកដ្ឋានពន្ធដារ សូមស្នើឲ្យអ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី មេត្តាចាត់ចែងដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំសម្រាប់ឆ្នាំជាប់ពន្ធ ២០១១ និងបង់ប្រាក់ពន្ធឲ្យបានរួសរាន់ទាន់ពេលវេលា ដើម្បីចៀសវាងនូវទោសទណ្ឌនានាទាក់ទិននឹងការយឺតយ៉ាវនៃការដាក់លិខិតប្រកាសឬការបង់ប្រាក់ពន្ធនេះ ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់លើស្មារតីសហប្រតិបត្តិការរបស់ អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១២

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708 / Fax: (855) 23 886 700